ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សុន្ទរកថាស្វាគមន៍

របស់ទេសរដ្ឋមន្ត្រី គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សហប្រធាននៃកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៨

វិមានរដ្ឋាភិបាល, រាជធានីភ្នំពេញ, ថ្ងៃទី ២-៣ ខែមីនា ឆ្នាំ ២០០៦

- សូមគោរពសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- លោកជំទាវ និងឯកឧត្តម ជាសហសេវិកក្នុងរាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ ប្រធានប្រតិភូ និងតំណាងដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍
- ឯកឧត្តម លោកជំទាវ លោក លោកស្រី

១- ជាបឋម ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្ស សូមសំដែងនូវកិច្ចស្វាគមន៍ចំពោះសមាជិក-សមាជិកានៃរាជរដ្ឋាភិបាល និង ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ទាំងអស់ ដែលបានមកជួបជុំគ្នានៅ **វិមានរដ្ឋាភិបាល** ដ៏ស្កឹមស្កៃនេះ ដើម្បីប្រារព្ធកិច្ចប្រជុំពិគ្រោះយោបល់លើកទី៨ បន្ទាប់ពីកិច្ចប្រជុំនៃ **គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍** (Government-Donor Coordination Committee -GDCC) ប្រកបដោយជោគជ័យ កាលពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៦ កន្លងមក ។ មុនចាប់ផ្តើមដំណើរការកិច្ចប្រជុំរបស់យើង ខ្ញុំសូមបកស្រាយនូវមនោសញ្ចេតនារបស់អង្គប្រជុំទាំងមូល ដើម្បីសំដែងនូវកត្តញ្ញូតាធម៌ និងគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតជូនសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី៨របស់យើងជាផ្លូវការ និង ថ្លែងសុន្ទរកថាគន្លឹះ ព្រមទាំងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់សំរាប់ការងាររួមរបស់យើងទាំងអស់គ្នា ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ ។

២- ឆ្នាំ២០០៦នេះ ជាឆ្នាំទី៨ ដែលប្រទេសកម្ពុជាបានរស់នៅក្នុងសន្តិភាពពេញលេញ និងឯកភាពទឹកដី ជារូបវន្ត និងជាស្ថាប័ន ។ កិច្ចប្រជុំនេះ ជាកិច្ចប្រជុំលើកទី៣ ដែលរាជរដ្ឋាភិបាលមានកិត្តិយសរៀបចំនៅក្នុងប្រទេស ហើយក៏ជាកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ សំរាប់រាជរដ្ឋាភិបាលនីតិកាលទី ៣

នៃរដ្ឋសភាដែរ ។ ជោគជ័យគួរឱ្យកត់សម្គាល់ ក្នុងចន្លោះកិច្ចប្រជុំពិគ្រោះយោបល់ គឺការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង កំណើនសេដ្ឋកិច្ចជាង ៧% នៅឆ្នាំ ២០០៥ ដែលសំរេចបានច្រើនហួសពីការប៉ាន់ប្រមាណនៅដើមឆ្នាំ២០០៥ ក្នុងពេលដែលកិច្ចព្រមព្រៀងវាយនភ័ណ្ឌពហុភាគីបានបញ្ចប់ និង ក្នុងពេលដែលឥទ្ធិពលអវិជ្ជមានខាងក្រៅមានសភាពធ្ងន់ធ្ងរណាស់ ពិសេសការកើនឡើងថ្លៃប្រេងឥន្ធនៈខ្ពស់បំផុត មិនធ្លាប់មាន និងការរាលដាលនៃជំងឺផ្តាសាយបក្សី ។ ជាមធ្យមភាគ ក្នុងរយៈមួយទសវត្សកន្លងទៅ កំណើនសេដ្ឋកិច្ចសំរេចបាន ៧% ក្នុងមួយឆ្នាំ គិតតាមថ្លៃថេរ ។ ឯកំណើនចំណូលក្នុងប្រជាជនម្នាក់ៗ បានកើនឡើងដោយគិតស្មើគ្នា ជាមធ្យម ៤,៥០% ប្រចាំឆ្នាំ គិតតាមថ្លៃថេរ ។ បើគិតធៀបប្រៀបលើផ្ទៃ ៥៦% នៃប្រទេស ដែលត្រូវបានធ្វើអង្កេតដូចគ្នា ចំនួនប្រជាជនកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្របានថយចុះពី ៣៩% នាឆ្នាំ១៩៩៣ មកត្រឹមតែ ២៨% ក្នុងឆ្នាំ២០០៤ ។ ក្នុងចន្លោះការប្រជុំពិគ្រោះយោបល់លើកទី ៧ មកលើក ទី៨ នេះ ការអនុវត្តន៍គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក្នុងឆ្នាំ ២០០៥ មានស្ថានភាពល្អប្រសើរ ដោយមានការកែលំអការប្រមូលចំណូល ការរឹតត្បិតចំណាយ និងការធ្វើវិចារណកម្មចំណាយលក្ខណៈជាប្រព័ន្ធ ។ ថវិកាឆ្នាំ ២០០៥ ត្រូវបានអនុវត្តយ៉ាងប្រយ័ត្នប្រយែងបំផុត ដើម្បីផ្តល់និកាសសម្រាប់ចំណាយ ជាអាទិភាពនានា ដូចជាវិស័យអប់រំ សុខាភិបាល កំណែទម្រង់មន្ត្រីរាជការ និងការស្តារ ការជួសជុល និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមទាំងប្រព័ន្ធស្រោចស្រពផង ។ កំណើនសេដ្ឋកិច្ចបាន និង កំពុងទទួលប្រយោជន៍ពីកំណែទម្រង់នានា ដែលរាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តយ៉ាងហ្មឹងម៉ាត់ ដែលរួមមាន **កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ** និង **ការអភិវឌ្ឍន៍វិស័យឯកជន** ជាពិសេសការធ្វើឱ្យប្រសើរឡើងនូវបរិស្ថានធុរកិច្ច និង ការវិនិយោគ កិច្ចសម្រួលពាណិជ្ជកម្ម ការចូលរួមរបស់វិស័យឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម រួមជាមួយ **កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់រដ្ឋបាល** និង **កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ** ។ ទាំងអស់នេះសំរេចទៅបានក្នុងសមោធាន នៃស្ថិរភាពនយោបាយ និងសុខសន្តិភាព សុទ្ធតែជាប្រការគន្លឹះបំផុតសម្រាប់កម្ពុជាបោះជំហានឆ្ពោះទៅមុខ ក្នុងការលើកកំពស់ការជីវភាព ការគោរពសិទ្ធិមនុស្ស ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការសំរេចឱ្យបាននូវកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព តាមការចង្អុលទិសនៃ **យុទ្ធសាស្ត្រចតុកោណ** របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ។

៣- នោះបើរាជរដ្ឋាភិបាលបានសំរេចសមិទ្ធផលជាច្រើន ក្នុងរយៈពេលមួយទសវត្សកន្លងទៅ ក៏ដូចជាក្នុងឆ្នាំ ២០០៥កន្លងមកក៏ដោយ ក៏រាជរដ្ឋាភិបាលនៅមានបញ្ហាប្រឈមដែលត្រូវជំនះដោះស្រាយក្នុងកិច្ចអភិវឌ្ឍន៍ ។ នោះ គឺការកាត់បន្ថយភាពក្រីក្រ ។ តាមការគណនានៅទូទាំងប្រទេស នៅមានអត្រាផល់

៣៥% នៅឡើយ ក្នុងឆ្នាំ ២០០៤ ពិតមែនតែវាបានចុះពីអត្រា ៤៧% កាលពីដប់ឆ្នាំមុន ។ ការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន និងការបែងចែកប្រកបដោយសមធម៌ នូវផ្លែផ្កានៃកិច្ចអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ច នៅតែកង្វល់ជាប្រចាំរបស់រាជរដ្ឋាភិបាល ។ ការបន្តកាត់បន្ថយកំរិតក្រីក្រ ពិសេសនៅតំបន់ជនបទ និងការលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជនឱ្យបានល្អប្រសើរ នៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។ ក្នុងនយោបាយ ពិពិធកម្មសេដ្ឋកិច្ច រាជរដ្ឋាភិបាល មិនភ្លេចទេនូវនវនីយកម្មបច្ចេកវិទ្យា និងសេដ្ឋកិច្ចពុទ្ធិ ដែលកំពុងពន្លកនោះទេ ។ ប៉ុន្តែ ការពន្លឿនកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម ដែលកំលាំងពលកម្មជាង៧០% កំពុងពឹងផ្អែកលើវិស័យនេះ ជាអាទិភាពខ្ពស់ និងបន្ទាន់បំផុតរបស់រាជរដ្ឋាភិបាល ។ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា មិនអាចសម្រេចបានឡើយ ប្រសិនបើគ្មានការបន្តបង្កើនជាដុំកំភួនទៀតនូវផលិតភាពដំណាំស្រូវ និង ការបង្វែរពីផលិតផលស្រូវ ទៅជាដំណាំផ្សេងៗទៀតក្នុងវិស័យកសិកម្ម ព្រមទាំងឧស្សាហកម្មកែច្នៃកសិផល ។ ហេតុនេះហើយបានជារាជរដ្ឋាភិបាល កំពុងរៀបចំឱ្យមានយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍវិស័យកសិកម្ម និងទឹកឱ្យបានឆាប់នាពេលខាងមុខ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏កំពុងផ្តល់អាទិភាពខ្ពស់ ចំពោះការប្រើប្រាស់ដីធ្លី ដែលជាបញ្ហាក្តៅគគុករបស់ប្រទេស នាពេលបច្ចុប្បន្ននេះ ។ រាជរដ្ឋាភិបាលដឹងច្បាស់ថា បើភាពក្រីក្រនៅតែបន្តអត្ថិភាព (Existence) ត្រាំត្រែងកំរិតខ្ពស់តទៅទៀតនោះ រាជរដ្ឋាភិបាល នឹងបាត់បង់កាលានុវត្តភាព ក្នុងការប្រើប្រាស់សក្តានុពលនៃធនធានសេដ្ឋកិច្ច និងធនធានមនុស្សដ៏មានតំលៃសំរាប់ការអភិវឌ្ឍន៍ប្រទេស ។ នេះមិនទាន់និយាយដល់ការប្រេះឆា ការបែកខ្ញែក និងអស្ថេរភាពក្នុងសង្គមផង ។

៤- លើសពីអ្វីៗទាំងអស់ រាជរដ្ឋាភិបាលបន្តប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ពីព្រោះថា អំពើពុករលួយបានបង្វែរធនធានពីអ្នកក្រទៅឱ្យអ្នកមាន ហើយវាធ្វើឱ្យអ្នកក្រនៅតែក្រ ។ ហេតុនេះហើយបានជានៅក្នុងតារាង **សូចនាករត្រួតពិនិត្យរួមគ្នា** (Joint Monitoring Indicators -JMI) ការប្រជុំលើកទី៦ នៃ **គណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍** (GDCC) នាថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៦ បានដាក់សូចនាករនេះជាករណីសំខាន់ ដែលត្រូវអនុវត្តបន្ត ទោះបីជា តារាងសូចនាករបានដាក់ "**ប្រសិទ្ធភាពនៃជំនួយនិងការពង្រឹងភាពជាដៃគូ** " នៅពីលើវាក៏ដោយ ។ សណ្តាប់ធ្នាប់នៅក្នុងសង្គម ជាកត្តាសំខាន់ណាស់នៃបរិស្ថានសំរាប់ការអភិវឌ្ឍន៍ ។ អាស្រ័យហេតុនេះហើយ សង្គ្រាមប្រឆាំងនឹងភាពក្រីក្រ និងសង្គ្រាមប្រឆាំងនឹងអំពើពុករលួយត្រូវដើរទន្ទឹមគ្នា ។ សង្គ្រាមនេះត្រូវធ្វើជាប្រចាំ ហើយវាមិនងាយនឹងមានចុងបញ្ចប់ទេ ។ ប៉ុន្តែក្នុងមួយដំណាក់កាលម្តងៗ យើងត្រូវ

មានគោលដៅច្បាស់លាស់ ។ **សូចនាករត្រួតពិនិត្យរួមគ្នា** (JMI) ជាឧបករណ៍សមស្របសំរាប់បំពេញកិច្ចការនេះ ។

៥- បញ្ហាបំណុលទាក់ទងទៅនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច គោលដៅសហសវត្សរ៍ និងការអភិវឌ្ឍន៍ និយាយជារួម ហើយទាក់ទងទៅនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និយាយដោយឡែក ។ ខ្ញុំសូមរំលឹកថា កម្ពុជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងទទួលការលើកលែងបំណុលក្នុងក្របខ័ណ្ឌការផ្តើមគំនិតរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដោយសារកម្ពុជាមានស្នាដៃនៅក្នុងការអនុវត្តន៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច មានវឌ្ឍនភាពល្អក្នុងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងការកែលំអក្នុងការគ្រប់គ្រងចំណាយសាធារណៈ ។ ដោយកម្ពុជាសំរេចបានលក្ខណៈសម្បត្តិទាំងនេះហើយ ទើបមូលនិធិរូបិយវត្ថុអន្តរជាតិ លុបបំណុលចំនួន ៨២លានដុល្លារអាមេរិក ។ ទន្ទឹមនឹងអំណរគុណសារជាថ្មី ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ យើងខ្ញុំសូមប្តេជ្ញាថា នឹងប្រើប្រាស់ធនធានបានមកពីការលុបបំណុលនេះ ឱ្យចំគោលដៅកាត់បន្ថយភាពក្រីក្រ ។ ក៏ប៉ុន្តែកម្ពុជាកំពុងរងសម្ពាធបំណុលឯទៀតដែរ ។ សម្ពាធបំណុលនេះមិនមែនកើតពីបំណុលក្រោយឆ្នាំ ១៩៩៣ ទេ ។ សម្ពាធបំណុលនេះ ស្ថិតត្រង់ថា កម្ពុជាត្រូវដោះស្រាយនិងជំរះលក្ខខ័ណ្ឌជាប់ជំពាក់មួយចំនួន ដែលម្ចាស់បំណុលចាស់ៗបានដាក់មកលើកម្ពុជា មុននឹងកម្ពុជាទទួលបាននូវការសំរេចរបស់មូលនិធិរូបិយវត្ថុអន្តរជាតិស្តីពី «កម្មវិធីកាត់បន្ថយ ភាពក្រីក្រ និងកំណើន» (Poverty Reduction and Growth Facility –PRGF) ទី២ សំរាប់កម្ពុជា ។ បំណុលចាស់ៗនេះមានបរិមាណជាសមាមាត្រធំធេងណាស់ធៀបប្រៀបនឹងបំណុលសរុប ។ វាជាបំណុលកើតចេញពីដែលបន្សល់ទុកដោយរបបមុន ហើយការដោះស្រាយបំណុលនេះនឹងជះឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេល ៤០ ឆ្នាំទៅមុខ ។ តែកម្ពុជានឹងខំមាត់សង្កត់ចិត្ត ខិតខំដោះស្រាយឱ្យទាល់តែបាន ដោយមិនគិតដល់សីលធម៌នៃបំណុល ឬសោកនាដកម្មរបស់ប្រជាជននៅជំនាន់នោះឡើយ ។ រាជរដ្ឋាភិបាលបានប្រកាសជាច្រើនដងហើយថា យើងខ្ញុំទទួលស្គាល់មរតករបស់រដ្ឋ ។ ក្នុងស្មារតីនេះ យើងខ្ញុំបានខិតខំដោះស្រាយបំណុលចាស់ទាំងឡាយរបស់កម្ពុជា ក្នុងជំហរមួយវិជ្ជមាន ហើយមានសង្គតិភាពជាប់ជានិច្ច ។ តែក្នុងការដោះស្រាយនេះ យើងខ្ញុំមានកាតព្វកិច្ចធានាកុំឱ្យដំណោះស្រាយនោះ វាមានបញ្ហាអាក្រក់ហួសហេតុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផង និងកុំឱ្យវាបង្អាក់បន្ទុចការអភិវឌ្ឍន៍ ក្នុងរយៈពេលវែងនៃប្រទេសយើងខ្ញុំខ្លាំងពេកផង ។ អាស្រ័យហេតុនេះ ការគ្រប់គ្រងបំណុលដោយប្រយ័ត្នប្រយែង គឺជាបញ្ហាសំខាន់ ដើម្បីឱ្យកម្ពុជាឈានទៅសំរេចបាននូវគោលដៅសហស្សវត្សរ៍កម្ពុជា និងការកាត់បន្ថយភាពក្រីក្រ ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមតាងនាមរាជរដ្ឋាភិបាល ដើម្បីសំដែងនូវកត្តញ្ញុតាធម៌ យ៉ាងជ្រាលជ្រៅ ចំពោះសាធារណរដ្ឋប្រជាមានិតចិន ដែលបានលុបបំណុលចាស់ចោលទាំងស្រុង ។

៦- រាជរដ្ឋាភិបាលបានអនុម័ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំរាប់ឆ្នាំ ២០០៦-២០១០** និង **កម្មវិធីវិនិយោគសាធារណៈឆ្នាំ ២០០៦-២០០៨** នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ បន្ទាប់ពីបានរៀបចំ និងពិភាក្សាយ៉ាងទូលំទូលាយក្នុងរាជរដ្ឋាភិបាលផង និងជាមួយដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍និងសង្គមស៊ីវិលផង ដើម្បីបន្តអនុវត្តកម្មវិធីនយោបាយ និង «**យុទ្ធសាស្ត្រចតុកោណ**» ។ រាជរដ្ឋាភិបាលសូមស្នើឱ្យដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ទាំងអស់ តម្រឹមយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ខ្លួន ឱ្យស្របនឹងបណ្តាអាទិភាព នៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និងសូមផ្តល់ហិរញ្ញប្បទានសំរាប់អនុវត្ត **កម្មវិធីវិនិយោគសាធារណៈ** ។ សំណូមពររបស់យើងខ្ញុំ គឺគ្មានអ្វីក្រៅពីខ្លឹមសារនៃសេចក្តីថ្លែងការណ៍ក្រុងប៉ារីស ខែមិនា ឆ្នាំ២០០៥ ស្តីពីប្រសិទ្ធភាពនៃជំនួយឡើយ ។ ខ្ញុំសូមបញ្ជាក់ម្តងទៀតថា រាជរដ្ឋាភិបាលនឹងបង្វែរធនធានដែលបានពីការលើកលែងបំណុលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ មកធ្វើការវិនិយោគដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដូចមានចែងច្បាស់ក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០** និង **កម្មវិធីវិនិយោគសាធារណៈឆ្នាំ២០០៦-២០០៨** ។

៧- ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយ គឺជាប្រធានបទមួយដែលមជ្ឈដ្ឋានអន្តរជាតិ ក៏ដូចជាប្រទេសទទួលជំនួយបាន និងកំពុងយកចិត្តទុកដាក់ខ្ពស់ ក្នុងរយៈពេល៣-៤ឆ្នាំកន្លងមកនេះ ។ នៅកម្ពុជាយើងបានអនុវត្តជំហានជាក់ស្តែងមួយចំនួនក្នុងកិច្ចការនេះ ។ ក្នុងរយៈពេលជាងមួយឆ្នាំ បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើកមុន រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការ នូវយន្តការសម្រាប់សម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ យន្តការនេះរួមមាន៖

ទី១) ក្រុមការងារបច្ចេកទេសតាមវិស័យ ឬតាមការដ្ឋានទាំងអស់ចំនួន ១៨ ។

ទី២) **គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍** (GDCC) សំរាប់សម្របសម្រួលកិច្ចការរបស់ក្រុមការងារបច្ចេកទេសទាំង ១៨ និងផ្តល់ការណែនាំកំរិតគោលនយោបាយ ។

៨- ការបង្កើតយន្តការក្រុមការងារបច្ចេកទេសចម្រុះ និង គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គឺជាការផ្លាស់ប្តូរជាសារវ័ន្ត ខាងផ្នែកស្ថាប័ន ខាងការរៀបចំផែនការការគ្រប់គ្រង និង ការត្រួតពិនិត្យវឌ្ឍនភាពស្តីពីការអនុវត្តន៍ជំនួយអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាម្ចាស់របស់កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការសំរាប់ពង្រឹងប្រសិទ្ធភាពជំនួយ ។ ក្រុមការងារទាំង១៨ និង **គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍** (GDCC) បានប្រជុំទៀងទាត់រៀងរាល់៣ខែម្តង ដើម្បីពិនិត្យរួមគ្នាអំពីវឌ្ឍនភាពធៀបនឹងផែនការសកម្មភាពរបស់ក្រុមការងារនិមួយៗ ព្រមទាំងពិនិត្យរួមគ្នា អំពីវឌ្ឍនភាពក្នុងការអនុវត្តន៍

ស្ងួចនាករតាមដានដែលបានឯកភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់កាលពីលើកមុន ។ កិច្ចប្រជុំលើកទី ៥ របស់ **គណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍** (GDCC) ដែលបានប្រព្រឹត្តទៅនាចុងឆ្នាំ២០០៥ បានផ្តល់បទពិសោធន៍ជាច្រើន ក្នុងការរៀបចំស្ងួចនាករតាមដានថ្មីសំរាប់កិច្ចប្រជុំលើកទី ៦ របស់ **គណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍** (GDCC) បានប្រព្រឹត្តទៅ នាថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៦ ដើម្បីយកមកសំរេចជាមួយគ្នា ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកនេះ ។ ដូចនេះ ការបន្តពង្រឹងយន្តការនេះ សំរាប់កែលំអដំណើរការកៀរគរ ការបែងចែក និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ នៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។

៩- សមិទ្ធផលមួយទៀត គឺការធ្វើសុខដុមភាវូបនីយកម្មជំនួយបរទេស ។ **ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល** លើកទី១ស្តីពី **សុខដុមនីយកម្ម** ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី នាថ្ងៃ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤កន្លងមក ហើយដៃគូអភិវឌ្ឍន៍ចំនួន១២ បានចុះហត្ថលេខាជាមួយរាជរដ្ឋាភិបាល នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤ ដើម្បីរួមអនុវត្តផែនការសកម្មភាពនេះ ។ ផ្អែកតាមវឌ្ឍនភាពមួយឆ្នាំកន្លងមក និងផ្អែកតាមភាពជាក់ស្តែងនៃកម្ពុជា ព្រមទាំងអនុលោមតាមគោលការណ៍ទាំង៥ នៃសេចក្តីប្រកាសទីក្រុងប៉ារីស នាខែមិនា ឆ្នាំ២០៥ **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** បានធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព នេះឡើងវិញ ដោយបានពិភាក្សារវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល និងជាមួយដៃគូអភិវឌ្ឍន៍ ហើយត្រូវបានអនុម័តដោយសម្តេចនាយករដ្ឋមន្ត្រី នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៦ ។ ខ្ញុំសូមការអនុញ្ញាត ពីសម្តេចនាយករដ្ឋមន្ត្រី ដើម្បីសំដែងនូវការវាយតំលៃខ្ពស់ ចំពោះឯកឧត្តម **ឈៀង យ៉ាណារ៉ា** ដែលបានស្ម័គ្រស្មោះ បំពេញ ការងារនេះ ក្នុងឋានៈជាប្រធាន **ក្រុមការងារភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ** ដែលបានរៀបចំផែនការសកម្មភាពនេះ ។ លើសពីនេះ ឯកឧត្តមជាប្រតិបត្តិករសំខាន់មួយ ក្នុងឋានៈជាតម្រង ក្នុងការរៀបចំតារាងស្ងួចនាករតាមដានរួមគ្នា ដែលជារបៀបវារៈសំខាន់មួយនៃកិច្ចប្រជុំរបស់ យើង និង ឯកសារដទៃទៀត ព្រមទាំងបានដឹកនាំកិច្ចសំរបសំរួលទាំងខាងបច្ចេកទេស និងទាំងខាងរដ្ឋបាល ជាមួយបណ្តាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាលនិងជាមួយដៃគូអភិវឌ្ឍន៍ សំរាប់កិច្ចដំណើរការប្រជុំនេះ ។ ការវាយតំលៃនេះមិនមែនតំរង់បុគ្គលទេ តែវាស្ថិតក្នុងបរិការណ៍នៃឯកសារ «**ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍**» ដែលរាជរដ្ឋាភិបាលបានអនុម័ត នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ហើយចង្អុលឱ្យ **គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គជសា/ក្រអក)** ជាចំណុចប្រមូលផ្តុំ ស្របតាមអនុក្រឹត្យលេខ ១៤៧ អនក្រ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៥ ។

១០- វឌ្ឍនភាពដែលកម្ពុជាសំរេចបានកន្លងមក គឺបានមកពីការប្តេជ្ញាចិត្តខ្ពស់ និងសកម្មភាពជាក់ស្តែង ចំទិស និងគោលដៅរបស់រាជរដ្ឋាភិបាល ក្រោមកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** រួមផ្សំជាមួយនឹងវិភាគទានដ៏ធំធេង និងជាតុចូលដ៏ថ្លៃថ្លា ពីសំណាក់ដៃគូអភិវឌ្ឍន៍ ។ អង្គប្រជុំយើងនឹងមានបុព្វសិទ្ធិ ត្រងត្រាប់ស្តាប់តាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នេះ ដើម្បីបានជាទុនសំរាប់កិច្ចពិភាក្សានៃកិច្ចប្រជុំរបស់យើង ។ ក្នុងន័យនេះ បន្ទាប់ពីអន្តរាគមន៍របស់សហប្រធាន **IAN C. PORTER** អង្គប្រជុំយើងនឹងមានកិត្តិយស សូមគោរពអញ្ជើញសម្តេចនាយករដ្ឋមន្ត្រី មេត្តាឡើងថ្លែងសន្ទរកថា និងផ្តល់សារគន្លឹះ ក្នុងឱកាសបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី៨នេះ ។

សូមអរគុណ !